Department of Health

health

# ធម្មនុញ្ញអតិថិជនប្រើប្រាស់សុរា និងគ្រឿងញៀនឯទៀត រដ្ឋវិចតូរីយ៉ា

## ក្នុងភាពជាជនដែលប្រើប្រាស់កិច្ចបំរើសុរា និងគ្រឿងញៀនឯទៀត (AOD) រដ្ឋវិចតូរីយ៉ា លោកអ្នកមានសិទ្ធិនឹង:

- ទទួលការផ្គត់ផ្គង់កិច្ចបំរើនៅក្នុងបរិស្ថានដែលមានសុវត្ថិភាព
- ទទួលការផ្គត់ផ្គង់កិច្ចបំរើនៅក្នុងលំនាំមួយដែលសមរម្យ ស្មោះត្រង់ ហើយគ្មានការវិនិច្ឆ័យ
- ទទួលការផ្គត់ផ្គង់កិច្ចបំរើដែលមានភាពស្និទ្ធស្នាល ហើយមានការគោរព
- ទទួលការផ្គត់ផ្គង់ព័ត៌មានគ្រប់គ្រាន់ស្តីអំពីកិច្ចបំរើ និងការព្យាបាលទាំងអស់ដែលមានផ្តល់
- ចូលរួមនៅក្នុងគ្រប់ទាំងទិដ្ឋភាពនៃការផ្តល់កិច្ចបំរើ
- ឲ្យគេរក្សាទុកព័ត៌មានអំពីលោកអ្នកដោយសម្ងាត់ លើកលែងតែត្រូវបានអនុញ្ញាតឲ្យបញ្ចេញផ្សេងពីនេះ
- ទទួលការផ្គត់ផ្គង់កិច្ចបំរើបានទាន់ពេល ហើយមានប្រសិទ្ធិភាពដែលឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់លោកអ្នក
- ធ្វើការប្តឹងតវ៉ា ហើយឲ្យគេដោះស្រាយការប្តឹងតវ៉ានោះដោយប្រសិទ្ធិភាព
- ទទួលការផ្គត់ផ្គង់កិច្ចបំរើដែលមានការដឹងពីវប្បធម៌ ដែលគិតបញ្ចូលទាំងតម្លៃសីលធម៌ និងសេចក្តីជំនឿរបស់លោកអ្នកផងដែរ។

## ក្នុងភាពជាជនដែលប្រើប្រាស់កិច្ចបំរើ AOD រដ្ឋវិចតូរីយ៉ា លោកអ្នកមានការទទួលខុសត្រូវ:

- ដើម្បីឲ្យមានការដឹងឮច្បាស់ជាមួយនឹងសិទ្ធិ និងការទទួលខុសត្រូវរបស់លោកអ្នក ក្នុងភាពជាជនដែលប្រើប្រាស់កិច្ចបំរើកិច្ចបំរើ AOD វិចតូរីយ៉ា
- រួមចំណែកដល់ការមើលថែបរិស្ថានសុវត្ថិភាព នៅក្នុងកិច្ចបំរើដែលលោកអ្នកប្រើប្រាស់
- ប្រព្រឹត្តចំពោះអ្នកឯទៀតដោយមានការគោរព និងការគួរសម
- ចូលរួមនៅក្នុងដំណើរការព្យាបាល ទៅតាមសមត្ថភាពប្រសើរបំផុតរបស់លោកអ្នក
- គោរពទៅតាមដំណើរការប្តឹងតវ៉ារបស់អង្គការ។ ប្រសិនបើលោកអ្នកមិនពេញចិត្តទេ លោកអ្នកអាចប្តឹងតវ៉ាទៅក្រៅបាន គឺទៅក្រសួងកិច្ចបំរើប្រជាពលរដ្ឋ ឬស្នងការកិច្ចបំរើសុខភាព។

ប្រសិនបើលោកអ្នកមានបំណងចង់ទទួលយកការចុះផ្សាយនេះ ក្នុងទម្រង់ដែលអាចប្រើប្រាស់បាន សូមទូរស័ព្ទលេខ 9096 5234 ឬអ៊ីម៉េល consumers@health.vic.gov.au

អនុញ្ញាតដោយរដ្ឋាភិបាលរដ្ឋវិចតូរីយ៉ា ម៉ែលប៊ន។

បោះពុម្ពដោយ Sovereign Press, 6 Traminer Court, Wendouree 3355.
ខែមីនា ឆ្នាំ២០១១ (1006037)

State Government Victoria